## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ថ្ងៃ ព្រហស្បតិ៍ ១២ រោច ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤*
*រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០២០*

# សេចក្តីប្រកាសព័ត៌មាន
# កិច្ចប្រជុំកំពូលអាស៊ាន-ជប៉ុន លើកទី ២៣
# ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០២០

នារសៀលថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០២០ នេះដែរ, ក្នុងនាមជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា, បន្ទាប់ពីកិច្ចប្រជុំកំពូលអាស៊ាន-ចិន, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ ចូលរួមកិច្ចប្រជុំកិច្ចកំពូល **"អាស៊ាន-ជប៉ុន លើកទី ២៣"** តាមប្រព័ន្ធវីដេអូ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ កិច្ចប្រជុំនេះដឹកនាំដោយឯកឧត្តម **ង្វៀន សួន ហ៊្វុក** (Nguyen Xuan Phuc) នាយករដ្ឋមន្ត្រីនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម ។

កិច្ចប្រជុំកំពូលនេះ បានគូសបញ្ជាក់អំពីសារសំខាន់នៃកិច្ចសហប្រតិបត្តិការរវាងអាស៊ាន និងជប៉ុន តាមរយៈការគាំទ្រដល់បណ្តាប្រទេសអាស៊ាន ក្នុងការលើកកម្ពស់សមត្ថភាពក្នុងកម្រិតប្រទេស និងតំបន់ ក្នុងការកាត់បន្ថយផលប៉ះពាល់ដែលបណ្តាលមកពីជំងឺកូវីដ-១៩ មកលើអាយុជីវិត និងលំនឹងជីវភាពរស់នៅរបស់ប្រជាជន ។ ថ្នាក់ដឹកនាំអាស៊ាន បានវាយតម្លៃខ្ពស់ដល់ប្រទេសជប៉ុនចំពោះ **"គំនិតផ្តួចផ្តើមសុខាភិបាលជប៉ុន-អាស៊ាន"** និង **"គំនិតផ្តួចផ្តើមសុខភាព និងសុខុមាលភាពអាស៊ី"** ព្រមទាំង បានថ្លែងអំណរគុណដល់មិត្តជប៉ុន ក្នុងការចូលរួមចំណែកគាំទ្រយ៉ាងសកម្មក្នុងការបង្កើត **"មជ្ឈមណ្ឌលអាស៊ានសម្រាប់ភាពបន្ទាន់ផ្នែកសុខភាពសាធារណៈ និងជំងឺថ្លងថ្មីៗ"** ។

ជាមួយគ្នានេះ, អង្គប្រជុំក៏បានពិភាក្សាអំពីអត្ថប្រយោជន៍ដ៏ធំធេងនៃគំនិតផ្តួចផ្តើមស្តីពី **"ការពង្រីកភាពជាដៃគូសម្រាប់ហេដ្ឋារចនាសម្ព័ន្ធប្រកបដោយគុណភាព និងផលវិជ្ជមានទៅលើរបៀបវារៈអភិវឌ្ឍន៍តំបន់"** ដែលនឹងបំពេញបន្ថែមដល់គំនិតផ្តួចផ្តើមសំខាន់ផ្សេងៗទៀតរបស់អាស៊ាន-ជប៉ុន ជាអាទិ៍ ដូចជា **"ផែនការមេស្តីពីការតភ្ជាប់អាស៊ាន**

**(MPAC) ២០២៥"** និង **"ទស្សនវិស័យអាស៊ានស្តីពីឥណ្ឌូ-ប៉ាស៊ីហ្វិក (AOIP)"** ជាដើម ។ អង្គប្រជុំ ក៏បានសង្កត់ធ្ងន់ផងដែរអំពីការប្តេជ្ញាចិត្តក្នុងការបន្តពង្រឹងកិច្ចសហប្រតិបត្តិការ តាមរយៈវេទិកា និងយន្តការអាស៊ាន រួមទាំងនៅក្នុងក្របខណ្ឌអាស៊ាន បូកបី (APT), ការចុះហត្ថលេខាលើ "ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP)", ការជួយគាំទ្រដល់ការរៀបចំផែនការការងារទី ៤ នៃ "គំនិតផ្តួចផ្តើមសមាហរណកម្មអាស៊ាន ឆ្នាំ ២០២១-២០២៥ (IAI Work Plan IV)" ព្រមទាំងគំនិតផ្តួចផ្តើមផ្សេងៗទៀត ដែលរួមមាន ដូចជា÷ "មូលនិធិជប៉ុនសម្រាប់សមាហរណកម្មអាស៊ាន", "កិច្ចសន្ទនាអាស៊ាន-ជប៉ុន ស្តីពីបដិវត្តន៍ឧស្សាហកម្មទី៤" និង "បណ្តាញទីក្រុងឆ្លាតអាស៊ាន (ASEAN Smart Cities Network- ASCN)" ជាដើម ។

ជាលទ្ធផល, ថ្នាក់ដឹកនាំបានធ្វើការកត់សម្គាល់អំពីសមិទ្ធផលធំធេង និង វឌ្ឍនភាពជាសារវ័ន្ត ដែលអាស៊ាន និងមិត្តជប៉ុន បានសម្រេចរួមគ្នា ដែលបានផ្តល់វិបុលភាពជូនប្រជាជននៃតំបន់ទាំងពីរ ។ កិច្ចប្រជុំកំពូលនេះ បានគាំទ្រ និងអនុម័តលើ÷ ១. ការបើកដំណើរការ និងបន្តគាំទ្រមជ្ឈមណ្ឌលអាស៊ានសម្រាប់ភាពបន្ទាន់ផ្នែកសុខភាពសាធារណៈ និងជំងឺឆ្លងថ្មីៗ; ២. ការប្តេជ្ញាគាំទ្រមជ្ឈភាព (ASEAN Centrality) និងអព្យាក្រឹតភាពរបស់អាស៊ាន និង ៣. សេចក្តីថ្លែងការណ៍រួមនៃកិច្ចប្រជុំកំពូលអាស៊ាន-ជប៉ុន លើកទី ២៣ ស្តីពីកិច្ចសហប្រតិបត្តិការលើចក្ខុវិស័យអាស៊ាន ស្តីពីឥណ្ឌូ-ប៉ាស៊ីហ្វិក ។